FRANCE ÉDUCATION INTERNATIONAL | DELF DALF



# បញ្ជាក់កម្រិតភាសា
# បារាំងរបស់លោកអ្នក
# ទទួលស្គាល់ជាអន្តរជាតិ!

- ត្រៀមខ្លួន
- ដើម្បីចូលប្រឡង

Liberté
Créativité
Diversité

INSTITUT FRANÇAIS
Cambodge

# តើលោកអ្នកកំពុងរៀន ឬបង្រៀនភាសាបារាំងមែនទេ?

**ការបញ្ជាក់ពីកម្រិតភាសារបស់លោកអ្នកគឺពិតជាចាំបាច់ណាស់សម្រាប់ការអនុវត្តគម្រោងរបស់លោកអ្នក៖**
ការសិក្សានៅប្រទេសបារាំង  ការដាក់បេក្ខភាពសម្រាប់កម្មវិធីផ្លាស់ប្តូរការសិក្សា គម្រោងជីវិតនៅក្នុងប្រទេសនិយាយភាសាបារាំង ការទទួលបានការងារថ្មី ឬក៏ក្លាយជាអ្នកកែកិច្ចការប្រឡង ឬអ្នកត្រួតពិនិត្យការប្រឡង។...

ដូច្នេះក្រសួងអប់រំជាតិ និងយុវជនផ្តល់ជូនវិញ្ញាបនបត្រ និងសញ្ញាបត្រជាភាសាបារាំងដែលជាភាសាបរទេស **ដើម្បីបញ្ជាក់ថាជំនាញភាសារបស់លោកអ្នកមានសុពលភាព** ចាប់ពីការសិក្សាដំបូង រហូតដល់កម្រិតខ្ពស់បំផុត។

សញ្ញាបត្រទាំងនេះដែលមាន**សុពលភាពអស់មួយជីវិត** និងសមស្របសម្រាប់មនុស្សគ្រប់វ័យ ត្រូវបាន**ទទួលស្គាល់ជាអន្តរជាតិ** ហើយត្រូវផ្តល់ជូននៅតាមមណ្ឌលប្រឡងជាង 1,200 កន្លែង តាមបណ្តាប្រទេស 175 ដោយអនុលោមតាមក្របខណ្ឌយោងទូទៅនៃសហភាពអឺរ៉ុប។

INSTITUT FRANÇAIS
Cambodge

*Liberté*
*Créativité*
*Diversité*

# មណ្ឌលប្រឡងផ្លូវការតែមួយគត់

*នៅប្រទេសកម្ពុជា វិទ្យាស្ថានបារាំងគឺជាមជ្ឈមណ្ឌលតែមួយគត់ ដែលផ្តល់ជូននូវសេវាចាំបាច់ទាំងអស់នេះសម្រាប់ភាពជោគជ័យរបស់លោកអ្នក៖*

- វគ្គរៀនត្រៀមសម្រាប់ប្រឡង DELF / DALF
- ការរៀបចំខ្លួនសម្រាប់ប្រឡង TCF
- មណ្ឌលប្រឡងប្រឡង DELF / DALF
- មជ្ឈមណ្ឌលប្រឡង TCF TP / IRN / កេបិច/ កាណាដា

# គុណសម្បត្តិរបស់វិទ្យាស្ថានបារាំង៖

- សាស្ត្រាចារ្យដែលកែកិច្ចការប្រឡង និងមេប្រយោគដែលមានសមត្ថភាពជាច្រើនរូប
- ដំណើរការដ៏មានគុណភាពដែលជំរុញដោយក្រសួងអប់រំជាតិ
- ការត្រួតពិនិត្យជាប្រចាំដោយស្ថានទូតបារាំងប្រចាំនៅកម្ពុជា

នៅក្នុងសៀវភៅមគ្គុទ្ទេសក៍នេះ លោកអ្នកនឹងទទួលបានព័ត៌មានសំខាន់ៗអំពីការប្រឡង DELF / DALF និង TCF ក៏ដូចជាជំណាក់កាលដែលត្រូវអនុវត្តសម្រាប់ការចុះឈ្មោះ។

**ព័ត៌មានបន្ថែម៖**

https://institutfrancais-cambodge.com/examens-et-certifications/

# DELF និង DALF

## *សញ្ញាបត្រសិក្សាភាសាបារាំង និងសញ្ញាបត្រជាន់ខ្ពស់ផ្នែកភាសាបារាំង*



## DELF/DALF Tout Public

### តើអ្វីទៅជា DELF / DALF Tout public ?

- សញ្ញាបត្រផ្លូវការចេញដោយក្រសួងអប់រំជាតិបារាំង
- កម្រិត៖ A1 A2 B1 B2 C1 និង C2
- មានសុពលភាពមួយជីវិត

*ឧទាហរណ៍នៃវិញ្ញាសា៖* ciep.fr/delf-dalf

### ហេតុអ្វីត្រូវប្រឡងយក DELF / DALF Tout public ?

- ដើម្បីសម្រេចគម្រោងរបស់លោកអ្នកនៅថ្នាក់ឧត្តមសិក្សាបារាំង

  *> អាហារូបករណ៍ (BGF, Eiffel, ពហុបច្ចេកទេស)*
- ចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរការសិក្សា

  *> សញ្ញាបត្រទ្វេដង ការស្ម័គ្រចិត្តរបស់ពលរដ្ឋ និងកម្មវិធីអន្តរជាតិ ...*
- ដើម្បីទទួលបានការងារនៅក្នុងទីផ្សារការងារកម្ពុជា ឬអន្តរជាតិ

  *> ប្រាក់ខែដល់ + 30% សម្រាប់លោកអ្នកដែលនិយាយភាសាបារាំង!*

### តើអ្នកណាខ្លះអាចប្រឡងយក DELF / DALF Tout public ?

- ជនបរទេស
- ជនជាតិបារាំងដែលមានដើមកំណើតពីប្រទេសដែលមិននិយាយភាសាបារាំង ហើយមិនមានសញ្ញាបត្រមធ្យមសិក្សា ឬឧត្តមសិក្សាសាធារណៈពីប្រទេសបារាំង

# តើត្រូវត្រៀមខ្លួនដោយរបៀបណា?

*ចូរត្រៀមខ្លួនសម្រាប់ការប្រឡងជាមួយវគ្គសិក្សាត្រៀម DELF ឬជាមួយថ្នាក់ពិសេស !*

- បង្កើនឱកាសប្រឡងជាប់ DELF / DALF រហូតដល់ 30%
- ការពង្រឹងផ្នែកភាសា ការប្រឡងសាកល្បង ការប្រឹក្សាយោបល់ ...

**ព័ត៌មានបន្ថែម៖** *infocours@institutfrancais-cambodge.com*
*+855 (0) 12 367 335 / 337*

## DELF Prim'

FRANCE EDUCATION INTERNATIONAL | DELF PRIM

### តើ DELF Prim គឺជាអ្វី?

- សញ្ញាបត្រផ្លូវការចេញដោយក្រសួងអប់រំជាតិបារាំង
- បម្រុងទុកសម្រាប់កុមារដែលមានអាយុពី 7 ដល់ 11 ឆ្នាំ៖ សម្ភារៈទាក់ទងនឹងល្បែងកម្សាន្ត ប្រធានបទជាក់លាក់សម្រាប់កុមារ
- កម្រិត៖ A1.1 A1 A2
- មានសុពលភាពមួយជីវិត

*ឧទាហរណ៍នៃវិញ្ញាសា៖* ciep.fr/delf-prim/

### ហេតុអ្វីត្រូវប្រឡង DELF Prim?

- ដើម្បីផ្តល់សុពលភាពជាផ្លូវការ និងអស់មួយជីវិតដល់ការរៀនភាសាបារាំងជាលើកដំបូងរបស់កូនលោកអ្នក
- ដើម្បីផ្តល់តម្លៃដល់ជំនាញទំនាក់ទំនងថ្មីជាភាសាបារាំងរបស់កូនលោកអ្នក
- បណ្តុះបណ្តាល និងផ្តល់ទំនុកចិត្តដល់កូនលោកអ្នក ក្នុងការប្រឡងភាសានាពេលអនាគត

## DELF Junior

FRANCE EDUCATION INTERNATIONAL | DELF JUNIOR

### តើ DELF Junior គឺជាអ្វី?

- សញ្ញាបត្រផ្លូវការចេញដោយក្រសួងអប់រំជាតិបារាំង
- បម្រុងទុក និងមានភាពសមស្របសម្រាប់ក្មេងជំទង់ អាយុពី 12 ដល់ 17 ឆ្នាំ
- កម្រិត៖ A1 A2 B1 B2
- មានសុពលភាពមួយជីវិត

*ឧទាហរណ៍នៃវិញ្ញាសា៖*
ciep.fr/delf-junior-scolaire/

### ហេតុអ្វីត្រូវប្រឡង DELF Junior?

- ដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ ឬ សាលាជាន់ខ្ពស់បារាំង
- ដើម្បីផ្តល់តម្លៃដល់ជំនាញទំនាក់ទំនងថ្មីជាភាសាបារាំងរបស់កូនលោកអ្នក
- បណ្តុះបណ្តាល និងផ្តល់ទំនុកចិត្តដល់កូនលោកអ្នក ក្នុងការប្រឡងភាសានាពេលអនាគត

# ខ្លឹមសារនៃវិញ្ញាសា

| | | /DELF A1* | រយៈពេល | ពិន្ទុ |
|---|---|---|---|---|
| វិញ្ញាសា | ស្ដាប់ | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារស្ដាប់ខ្លីៗ ចំនួន 3 ឬ 4 ដែលទាក់ទងនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ (ស្ដាប់បានពីរដង)<br><br>រយៈពេលអតិបរមានៃឯកសារគឺ ▸ 3 នាទី | ប្រហែល 20 នាទី | /25 |
| | អាន | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារជាសំណេរចំនួន 4 ឬ 5 ដែលទាក់ទងនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ។ | ប្រហែល 30 នាទី | /25 |
| វិញ្ញាសា | សំណេរ | វិញ្ញាសាចែកជាពីរផ្នែកៈ<br>• *បំពេញតារាងឯកសារមួយច្បាប់ ទម្រង់បែបបទមួយច្បាប់*<br>• *តាក់តែងឃ្លាប្រយោគសាមញ្ញ (កាតប៉ុស្ដាល់ សារ រឿងនិទាន... ) ទាក់ទងទៅនឹងប្រធានបទនៃជីវិតប្រចាំថ្ងៃ* | 30 នាទី | /25 |
| | និយាយ | វិញ្ញាសាចែកជាបីផ្នែកៈ<br>• *ការសម្ភាសន៍ដែលមានរចនាសម្ព័ន្ធ តាមបញ្ជីសំណួរ*<br>• *ការផ្លាស់ប្ដូរព័ត៌មាន*<br>• *ការសន្ទនាដោយដើរតួរ* | 5 ទៅ 7 នាទី<br><br>រយៈពេលត្រៀមៈ 10នាទី | /25 |

**កំណត់សម្គាល់សម្រាប់គ្រប់កម្រិត៖**

ពិន្ទុសរុបលើ 100 កម្រិតពិន្ទុជាប់សម្រាប់ទទួលបានសញ្ញាបត្រ៖ 50/100

ពិន្ទុអប្បបរមាដែលអាចទទួលយកបានសម្រាប់វិញ្ញាសានីមួយៗ៖ 5/25

* សម្រាប់ DELF Prim A1.1 សូមមើល៖ http://www.ciep.fr/delf-prim

FRANCE EDUCATION INTERNATIONAL | DELF DALF

| | | /DELF A2 | រយៈពេល | ពិន្ទុ |
| --- | --- | --- | --- | --- |
| វិញ្ញាសា | ស្តាប់ | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារស្តាប់ដែលទាក់ទងនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ (ស្តាប់ពីរដង)<br>រយៈពេលអតិបរមានៃឯកសារគឺ ➤ 5 នាទី | ប្រហែល 25 នាទី | /25 |
| | អាន | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារសំណេរខ្លីៗ ជាច្រើនដែលទាក់ទងនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ | 30 នាទី | /25 |
| វិញ្ញាសា | សំណេរ | វិញ្ញាសាទាក់ទងនឹងការពិពណ៌នា (ព្រឹត្តិការណ៍ បទពិសោធន៍ផ្ទាល់ខ្លួន... ) និង ការសន្ទនា (ការអញ្ជើញ អរគុណ សុំទោស ស្នើសុំ សួរ ផ្តល់ដំណឹង សរសើរ... ) | 45 នាទី | /25 |
| | និយាយ | វិញ្ញាសាចែកជាបីផ្នែក៖<br>• *ការសម្ភាសន៍ដែលមានរចនាសម្ព័ន្ធតាមបញ្ជីសំណួរ*<br>• *ការនិយាយតែម្នាក់ឯងទាក់ទងទៅនឹងអ្វីមួយ*<br>• *លំហាត់ទាក់ទងទៅនឹងការសន្ទនា* | 6 ទៅ 8 នាទី<br>រយៈពេលត្រៀម៖ 10នាទី | /25 |

# ខ្លឹមសារនៃវិញ្ញាសា

| | | /DELF B1 | រយៈពេល | ពិន្ទុ |
|---|---|---|---|---|
| វិញ្ញាសា | ស្ដាប់ | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារស្ដាប់ជាច្រើន (ស្ដាប់ពីរដង)<br>រយៈពេលអតិបរមានៃឯកសារគឺ ➤ 6 នាទី | ប្រហែល 25 នាទី | /25 |
| | អាន | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារសំណេរជាច្រើន<br>• *ទាញយកព័ត៌មានសំខាន់ៗទាក់ទងនឹងកិច្ចការដែលបានផ្ដល់ជូន*<br>• *វិភាគខ្លឹមសារនៃឯកសារតាមអត្ថន័យទូទៅ* | 45 នាទី | /25 |
| វិញ្ញាសា | សំណេរ | វិញ្ញាសាទាក់ទងនឹងសំណេរពីទស្សនៈផ្ទាល់ខ្លួនលើប្រធានបទទូទៅមួយ (អត្ថបទត្រិះរិះ, សំបុត្រ, អត្ថបទការសែត ... ) | 45 នាទី | /25 |
| | និយាយ | វិញ្ញាសាចែកជាបីផ្នែក៖<br>• *ការសម្ភាសន៍ដែលមានរចនាសម្ព័ន្ធតាមបញ្ជីសំណួរ*<br>• *លំហាត់ទាក់ទងទៅនឹងការសន្ទនា*<br>• *ការបង្ហាញទស្សនៈទាក់ទងឯកសារគន្លឹះអ្វីមួយ* | 15 នាទី<br>រយៈពេលត្រៀម៖ 10 នាទី | /25 |

**កំណត់សម្គាល់សម្រាប់គ្រប់កម្រិត៖**

ពិន្ទុសរុបលើ 100 កម្រិតពិន្ទុជាប់សម្រាប់ទទួលបានសញ្ញាបត្រ៖ 50/100
ពិន្ទុអប្បបរមាដែលអាចទទួលយកបានសម្រាប់វិញ្ញាសានីមួយៗ៖ 5/25

FRANCE EDUCATION INTERNATIONAL | DELF DALF

| | | /DELF B2 | រយៈពេល | ពិន្ទុ |
|---|---|---|---|---|
| វិញ្ញាសា | ស្តាប់ | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងឯកសារស្តាប់ជាច្រើន (ស្តាប់ពីរដង)<br>រយៈពេលអតិបរមានៃឯកសារគឺ ➤ 15 នាទី | ប្រហែល 30 នាទី | /25 |
| | អាន | ឆ្លើយតបទៅនឹងកម្រងសំណួរ ស្វែងយល់ដែលទាក់ទងនឹងអត្ថបទសំណេរជាច្រើន | 1ម៉ោង | /25 |
| វិញ្ញាសា | សំណេរ | សរសេរអំពីគោលជំហរផ្ទាល់ខ្លួនជាមួយនឹងអំណះអំណាង (ការចូលរួមនឹងការតស៊ូមតិ សំបុត្រផ្លូវការ អត្ថបទរិះគន់) | 1ម៉ោង | /25 |
| | និយាយ | ធ្វើការបង្ហាញ និងការពារទស្សនៈផ្ទាល់ខ្លួនមួយដោយផ្អែកលើឯកសារគន្លឹះខ្លីណាមួយ | 20 នាទី<br>រយៈពេលត្រៀម៖ 30 នាទី | /25 |

# ខ្លឹមសារនៃវិញ្ញាសា

| | | /DALF C1 | រយៈពេល | ពិន្ទុ |
|---|---|---|---|---|
| វិញ្ញាសាស្តាប់ | ស្តាប់ | កម្រងសំណួរស្វែងយល់ពាក់ព័ន្ធនឹងឯកសារស្តាប់ជាច្រើន<br>• *ឯកសារស្តាប់ដ៏វែងមួយ (ការសម្ភាសន៍ វគ្គសិក្សា សន្និសីទ ...) មានរយៈពេលប្រហែល 8 នាទី (ស្តាប់ពីរដង)*<br>• *ឯកសារស្តាប់ខ្លីៗជាច្រើន (ការផ្សាយព័ត៌មានខ្លីៗ ការស្ទាបស្ទង់ ការផ្សាយពាណិជ្ជកម្ម... ) (ស្តាប់មួយដង)*<br>រយៈពេលអតិបរមានៃឯកសារគឺ ➤ 10 នាទី | ប្រហែល 40 នាទី | /25 |
| | អាន | ឆ្លើយតបទៅនឹងកម្រងសំណួរស្វែងយល់ទាក់ទងនឹងអត្ថបទអំពីគំនិតអ្វីមួយ (អក្សរសាស្ត្រ ឬសារព័ត៌មាន) ដែលមានពី 1,500 ទៅ 2,000 ពាក្យ | 50 នាទី | /25 |
| វិញ្ញាសា | សំណេរ | វិញ្ញាសាចែកជាពីរផ្នែក៖<br>• *ធ្វើការសំយោគពីឯកសារសំណេរជាច្រើនឱ្យបានប្រហែល 1,000 ពាក្យ*<br>• *សរសេរអត្ថបទអំណះអំណាងដោយផ្អែកលើខ្លឹមសារឯកសារជាច្រើន* | 2 ម៉ោង 30 នាទី | /25 |
| | និយាយ | ការធ្វើបទបង្ហាញដោយផ្អែកលើឯកសារសំណេរអមជាច្រើន បន្ទាប់មកធ្វើការពិភាក្សាជាមួយគណៈវិនិច្ឆ័យ | 30 នាទី<br>រយៈពេលត្រៀម៖ 1 ម៉ោង | /25 |

**កំណត់សម្គាល់សម្រាប់គ្រប់កម្រិត៖**

ពិន្ទុសរុបលើ 100 កម្រិតពិន្ទុជាប់សម្រាប់ទទួលបានសញ្ញាបត្រ៖ 50/100

ពិន្ទុអប្បបរមាដែលអាចទទួលយកបានសម្រាប់វិញ្ញាសានីមួយៗ៖ 5/25 និង 10/50

FRANCE EDUCATION INTERNATIONAL | DELF DALF

| | | /DALF C2 | រយៈពេល | ពិន្ទុ |
|---|---|---|---|---|
| វិញ្ញាសាស្តាប់ និង និយាយ | ស្តាប់ | វិញ្ញាសាចែកជាបីផ្នែក៖<br>• *ធ្វើរបាយការណ៍អំពីខ្លឹមសារនៃឯកសារស្តាប់មួយ (ស្តាប់ពីរដង)*<br>• *ធ្វើការអភិវឌ្ឍមតិផ្ទាល់ខ្លួនផ្អែកលើប្រធានបទ ដែលមាននៅក្នុងឯកសារស្តាប់*<br>• *ធ្វើការតស៊ូមតិជាមួយគណៈវិនិច្ឆ័យ* | 50 នាទី<br>ត្រៀម៖<br>1 ម៉ោង | /50 |
| វិញ្ញាសាអាន និង សរសេរ | អាន និង សរសេរ | តាក់តែងអត្ថបទ សំណេរមួយ ផ្អែកលើអត្ថបទផ្សេងៗ (អក្សរសាស្ត្រ ឬសារព័ត៌មាន) ដែលមានប្រហែល 2,000 ពាក្យ | 3ម៉ោងកន្លះ | /50 |

# TCF

*ការធ្វើតេស្តចំណេះដឹងអំពីភាសាបារាំង*

ខុសពី DELF / DALF ដែលផ្តល់ជាកម្រិតទូទៅ TCF កំណត់**កម្រិតទូទៅ** និង**កម្រិតតាមជំនាញ**។ TCF មាន**សុពលភាពរយៈពេលត្រឹមពីរឆ្នាំ** ដូច្នេះផ្តល់នូវរូបភាពថ្មីៗនៃកម្រិតភាសាបារាំងរបស់លោកអ្នក។

## ដោយផ្អែកលើគោលបំណងរបស់លោកអ្នក មានតេស្ត TCF ជាច្រើនដែលលោកអ្នកអាចប្រើប្រាស់បាន៖

- TCF Tout Public
- TCF IRN
- TCF កេបិច
- TCF កាណាដា



FRANCE ÉDUCATION INTERNATIONAL | TCF

# TCF
# Tout Public

## តើ TCF Tout Public ជាអ្វី?

- តេស្តវាយតម្លៃជំនាញភាសាបារាំងទូទៅពីកម្រិត A1 ដល់កម្រិត C2
- សុពលភាពរយៈពេលពីរឆ្នាំ
- ត្រូវរង់ចាំ 30 ថ្ងៃ រវាងការប្រឡងចំនួន 2 ដង

## ហេតុអ្វីត្រូវប្រឡង TCF Tout Public?

- ដើម្បីវាយតម្លៃចំណេះដឹងភាសាបារាំងរបស់លោកអ្នក
- ដើម្បីធ្វើឱ្យជំនាញរបស់លោកអ្នកមានតម្លៃនៅក្នុងអាជីពការងារ
- ដើម្បីបន្តការសិក្សាទៅសកលវិទ្យាល័យបារាំង

## តើលោកអ្នកណាអាចប្រឡង TCF បាន?

- ក្មេងជំទង់ (ចាប់ពីអាយុ 16 ឆ្នាំ) និងមនុស្សពេញវ័យដែលភាសាបារាំងមិនមែនជាភាសាកំណើត

## តើមានវិញ្ញាសាអ្វីខ្លះ / តើការប្រឡងត្រូវបានបង្ហាញយ៉ាងដូចម្តេច?

- **វិញ្ញាសាជាកាតព្វកិច្ចមានចំនួន 3** (76 សំណួរ - 1 ម៉ោង 25 នាទី) :
  > *វិញ្ញាសាស្តាប់* 29 សំណួរ / 25 នាទី
  > *គុណភាពនៃរចនាសម្ព័ន្ធភាសា* 18 សំណួរ / 15 នាទី
  > *វិញ្ញាសាអាន* 29 សំណួរ / 45 នាទី
- **វិញ្ញាសាបន្ថែម 2**
  > *វិញ្ញាសានិយាយ រយៈពេល* 12 នាទី
  > *វិញ្ញាសាសំណេរ រយៈពេល* 60 នាទី

## តើត្រូវត្រៀមខ្លួនយ៉ាងដូចម្តេច?

វគ្គសិក្សាសម្រាប់បុគ្គលម្នាក់ៗ ដើម្បីត្រៀមប្រឡង TCF

**ព័ត៏មានបន្ថែម៖**

infocours@institutfrancais-cambodge.com
+855 (0) 12 367 335 / 337

បញ្ជីឯកសារយោង និងគេហទំព័រ៖ **www.ciep.fr/tcf**

FRANCE ÉDUCATION INTERNATIONAL | TCF INTÉGRATION, RÉSIDENCE & NATIONALITÉ



# TCF

## TCF ដើម្បីទទួលបានសញ្ជាតិបារាំង ឬ រស់នៅបារាំង (IRN)

### តើ TCF IRN គឺជាអ្វី?

- តេស្តវាយតម្លៃជំនាញភាសាបារាំងរបស់លោកអ្នកដែលដាក់ពាក្យស្នើសុំសញ្ជាតិបារាំង
- មានសុពលភាពរយៈពេលពីរឆ្នាំ

### ហេតុអ្វីត្រូវប្រឡង TCF IRN?

- សម្រាប់ការស្នើសុំសញ្ជាតិបារាំង
- ដើម្បីបានកម្រិតភាសា A1 អាចរស់នៅបារាំង

### តើអ្នកណាអាចប្រឡង TCF IRN បាន?

- ជនបរទេសដែលមានអាយុចាប់ពី ១៦ឆ្នាំ

*ករណីលើកលែងមាននៅលើ គេហទំព័រ៖*
ciep.fr/tcf-irn

### តើមានវិញ្ញាសាអ្វីខ្លះ / តើការប្រឡងត្រូវបានបង្ហាញយ៉ាងដូចម្តេច?

- វិញ្ញាសាជាកាតព្វកិច្ចមានចំនួន 4៖

> *វិញ្ញាសាស្តាប់*
> 20 សំណួរ / 15 នាទី

> *វិញ្ញាសាអាន*
> 20 សំណួរ / 20 នាទី

> *វិញ្ញាសាសំណេរ*
> 3 កិច្ចការ / 30 នាទី

> *វិញ្ញាសានិយាយ*
> 3 កិច្ចការ / 10 នាទី

### តើត្រូវត្រៀមខ្លួនយ៉ាងដូចម្តេច?

- វគ្គសិក្សាសម្រាប់បុគ្គលម្នាក់ៗ ដើម្បីត្រៀមប្រឡង TCF

**ព័ត៏មានបន្ថែម៖**

infocours@institutfrancais-cambodge.com
+855 (0) 12 367 335 / 337

FRANCE ÉDUCATION INTERNATIONAL | TCF QUÉBEC

# TCF
# កេបិច

## តើ TCF កេបិចគឺជាអ្វី?

- តេស្តវាយតម្លៃជំនាញភាសាបារាំងរបស់លោកអ្នកដែលដាក់ពាក្យសុំអន្តោប្រវេសន៍ទៅកាន់ខេត្តកេបិច
- មានសុពលភាពរយៈពេលពីរឆ្នាំ

## ហេតុអ្វីត្រូវប្រឡង TCF កេបិច?

- សម្រាប់ដាក់ពាក្យស្នើសុំធ្វើអន្តោប្រវេសន៍ទៅខេត្តកេបិច

## តើអ្នកណាអាចប្រឡង TCF កេបិចបាន?

- លោកអ្នកដែលមានបំណងធ្វើអន្តោប្រវេសន៍ទៅខេត្តកេបិច

*ការលើកលែងអាចធ្វើបាន ប្រសិនបើមាន TCF TP DELF DALF៖* ciep.fr/tcf-quebec

## តើមានវិញ្ញាសាអ្វីខ្លះ / តើការប្រឡងត្រូវបានបង្ហាញយ៉ាងដូចម្តេច?

- វិញ្ញាសាពី 1 ដល់ 4៖
  - > *វិញ្ញាសាស្តាប់*
    39 សំណួរ / 35 នាទី
  - > *វិញ្ញាសាអាន*
    39 សំណួរ / 60 នាទី
  - > *វិញ្ញាសានិយាយ*
    3 កិច្ចការ / 12 នាទី
  - > *វិញ្ញាសាសំណេរ*
    3 កិច្ចការ / 60 នាទី
- ចាប់តាំងពីឆ្នាំ 2013 មក កម្រិត B2 គឺចាំបាច់ដើម្បីទទួលបានពិន្ទុសរុប 16 សម្រាប់ការវាយតំលៃភាសានេះ។

## តើត្រូវត្រៀមខ្លួនយ៉ាងដូចម្តេច?

> វគ្គសិក្សាសម្រាប់បុគ្គលម្នាក់ៗ ដើម្បីត្រៀមប្រឡង TCF

**ព័ត៌មានបន្ថែម៖**

infocours@institutfrancais-cambodge.com
+855 (0) 12 367 335 / 337

FRANCE EDUCATION INTERNATIONAL | TCF CANADA

# TCF កាណាដា

## តើ TCF កាណាដាជាអ្វី?

- តេស្តវាយតម្លៃជំនាញភាសាបារាំងរបស់លោកអ្នកដែលដាក់ពាក្យស្នើសុំអន្តោប្រវេសន៍ទៅប្រទេសកាណាដា
- មានសុពលភាពរយៈពេលពីរឆ្នាំ

## ហេតុអ្វីត្រូវប្រឡង TCF កាណាដា?

- ដើម្បីដាក់ពាក្យស្នើសុំអន្តោប្រវេសន៍សេដ្ឋកិច្ច ឬដើម្បីទទួលបានសញ្ជាតិកាណាដានៅឯក្រសួងអន្តោប្រវេសន៍ជនភៀសខ្លួន និងសញ្ជាតិកាណាដា (IRCC)

## តើអ្នកណាអាចប្រឡង TCF កាណាដាបាន?

- លោកអ្នកដែលចង់ធ្វើអន្តោប្រវេសន៍ទៅកាន់ប្រទេសកាណាដា
- មិនអាចមានការលើកលែងបានទេ

## តើមានវិញ្ញាសាអ្វីខ្លះ / តើការប្រឡងត្រូវបានបង្ហាញយ៉ាងដូចម្តេច?

- **វិញ្ញាសាកាតព្វកិច្ចចំនួន 4៖**
  - > *វិញ្ញាសាស្តាប់*
    39 សំណួរ / 35 នាទី
  - > *វិញ្ញាសាអាន*
    39 សំណួរ / 60 នាទី
  - > *វិញ្ញាសានិយាយ*
    3 កិច្ចការ / 12 នាទី
  - > *វិញ្ញាសាសំណេរ*
    3 កិច្ចការ / 60 នាទី
- កម្រិតដែលអាចទទួលយកបានសម្រាប់ការធ្វើអន្តោប្រវេសន៍ទៅកាន់ប្រទេសកាណាដាត្រូវបានបញ្ជាក់នៅលើគេហទំព័រ៖ ciep.fr/tcf-canada

## តើត្រូវត្រៀមខ្លួនយ៉ាងដូចម្តេច?

វគ្គសិក្សាសម្រាប់បុគ្គលម្នាក់ៗដើម្បីត្រៀមប្រឡង TCF

**ព័ត៌មានបន្ថែម៖**

infocours@institutfrancais-cambodge.com
+855 (0) 12 367 335 / 337

# តើត្រូវចុះឈ្មោះប្រឡងយ៉ាងដូចម្តេច?

*ចំពោះការប្រឡងផ្លូវការនៃភាសាបារាំង DELF / DALF ឬ TCF*

សូមទាក់ទងទៅមជ្ឈមណ្ឌលប្រឡងថ្នាក់ជាតិ ឬកន្លែងប្រឡង របស់មណ្ឌលប្រឡងថ្នាក់ជាតិដែលជាស្ថាប័ន ទទួលបានការអនុញ្ញាតឱ្យធ្វើការប្រឡងជាផ្លូវការជាភាសាបារាំងនៅប្រទេសកម្ពុជា។

## មជ្ឈមណ្ឌលប្រឡងថ្នាក់ជាតិ

- ***មជ្ឈមណ្ឌលភាសានៃវិទ្យាស្ថានបារាំងនៅកម្ពុជា***
218 ផ្លូវ 184 - ប្រអប់សំបុត្រលេខ 827
ទីក្រុងភ្នំពេញ

***ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ៖***
ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 7 ល្ងាច
***ថ្ងៃសៅរ៍៖***
ពីម៉ោង 8 ព្រឹក ដល់ ម៉ោង 12 ថ្ងៃត្រង់

***លេខទូរសព្ទ៖*** +855 (0) 12 367 335 / 337

infocours@institutfrancais-cambodge.com
institutfrancais.ducambodge

## កន្លែងប្រឡងដែលបានការអនុញ្ញាត

***មជ្ឈមណ្ឌលភាសាបាត់ដំបង***
លេខ 180 ផ្លូវ 501 ក្រុម 41
ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ

***លេខទូរសព្ទ៖*** +855 (0) 53 952 897
battambang@institutfrancais-cambodge.com

INSTITUT FRANÇAIS
Cambodge

# ក្លាយជា
# អ្នកកែកិច្ចការប្រឡង និងមេប្រយោគ !

*តើលោកអ្នកបង្រៀនភាសាបារាំង ហើយចង់ក្លាយជាអ្នកកែកិច្ចការប្រឡង ឬមេប្រយោគសម្រាប់ការប្រឡង **DELF/DALF** ដែរឬទេ ?*

**សូមចូលរួមវគ្គបណ្តុះបណ្តាលដែលមានការទទួលស្គាល់ទូទាំងពិភពលោក ហើយមានសុពលភាពរយៈពេល 5 ឆ្នាំ!**

# ជំហានទី 1

ត្រូវប្រាកដថាលោកអ្នកស្ថិតក្នុងស្ថានភាពមួយក្នុងចំណោមស្ថានភាពដូចខាងក្រោម៖

**1/** *មានសញ្ញាបត្រអនុបណ្ឌិតបង្រៀនភាសាបារាំងជាភាសាបរទេស (FLE) ឬភាសាបរទេស*

**2/** *មានសញ្ញាបត្របង្រៀនភាសាបារាំងជាភាសាបរទេស ដែលមានបទពិសោធន៍គួរឱ្យកត់សម្គាល់ជាង 2 ឆ្នាំ ក្នុងការបង្រៀន*

**3/** *មានបទពិសោធន៍គួរឱ្យកត់សម្គាល់ចាប់ពី 3 ឆ្នាំឡើងក្នុងការបង្រៀនភាសាបារាំង ជាភាសាបរទេស*

# ជំហានទី 2

ដាក់ពាក្យស្នើសុំចុះឈ្មោះជាមួយវិទ្យាស្ថានបារាំងនៅកម្ពុជា ទៅកាន់អ៊ីមែល៖

certifications@institutfrancais-cambodge.com

# ជំហានទី 3

វិទ្យាស្ថានភាសាបារាំងនៅកម្ពុជាផ្ញើពាក្យសុំចុះឈ្មោះ ទៅលោកអ្នក។

# ជំហានទី 4

បំពេញពាក្យសុំចុះឈ្មោះ ដោយភ្ជាប់មកជាមួយនូវឯកសារដែលបានស្នើសុំ។



INSTITUT FRANÇAIS
Cambodge

AMBASSADE DE FRANCE AU CAMBODGE
*Liberté*
*Égalité*
*Fraternité*


**ភ្នំពេញ**
218 ផ្លូវ 184
+855 (0)23 985 611/612
Institut français du Cambodge

**បាត់ដំបង**
លេខ 180 ផ្លូវ 501 ក្រុម 41
ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ
+855 (0)53 952 897